**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សាលក្រមព្រហ្មទណ្ឌលេខ: ៥០ "ច"
ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥

# តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជាសាធារណៈនៅទីសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងប្រកាសសាលក្រមនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ០៩ព្រឹក ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ១០០០ អក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ប៉េង ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រែកឈ្មោះ ឃុំព្រែករៃ ស្រុកល្វាឯម ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តកណ្តាល មុខរបរ ជាជំទប់ទី២ឃុំបន្ទាយដែក មានប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] (រស់) ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

-ជាប់ចោទពីបទ: "ការលួចរត់" ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តកណ្តាល ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៦០, ៥៦១ នៃក្រមព្រហ្មទណ្ឌ ។

២-ឈ្មោះ [redacted] ផូនី ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រះប្រសព្វ ឃុំព្រះប្រសព្វ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ន [redacted] សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរ [redacted] នៅលីវ ឪពុកឈ្មោះ [redacted] ស្លាប់ ម្តាយឈ្មោះ [redacted] (រស់) ទោសពីមុន គ្មាន ។ (ក្រៅឃុំ)



Scanned by CamScanner

៣-ឈ្មោះ [redacted] ថេង ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិចិន ឃុំសន្ទុង ស្រុកត្រាំង ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នផ្ទះ [redacted] ខណ្ឌដូនពេញ រាជធានីភ្នំពេញ មុខរបរ ជាតំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល មានប្រពន្ធឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] (ស្លាប់) ម្ដាយឈ្មោះ [redacted] ស្លាប់) ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

-ជាប់ចោទពីបទៈ "ផ្ដល់មធ្យោបាយលួចរត់" ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តកណ្ដាល ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥៦៥ នៃក្រមព្រហ្មទណ្ឌ ។

-ដោយមានលោកមេធាវី [redacted] ធារី, លោកមេធាវី [redacted] ផុនធី, លោកមេធាវី [redacted] មុនិន្ទ, លោកមេធាវី [redacted] វណ្ណៈ, លោកមេធាវី [redacted] បញ្ញា, លោកមេធាវី [redacted] សារី, លោកមេធាវី [redacted] ឈុនហាក់ និង លោកមេធាវី [redacted] សំអឿន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ដូនី ។

-លោកមេធា[redacted] ឃី, លោកមេធាវី [redacted] លន់ និងលោកមេធាវី [redacted] វុទ្ធី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ថេង ។

-បានឃើញដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៤៣ ដកដណស្រ ចុះថ្ងៃ-ទី១៥ ខែមិថុនា ឆ្នាំ២០១២ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះបន្តលេខ ១១៥ ដកចត/១៤ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ។

-បានឃើញកំណត់ហេតុសវនាការ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ។

**អង្គហេតុ**

នៅថ្ងៃទី២២ និងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ចៅក្រមស៊ើបសួរលោក លឹម សុគន្ធា បានសួរចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៉េង ពីបទៈ ផ្ដួចផ្ដើមគំនិតប្រើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយ-សុចរិត តាមដីកាបង្គាប់ឲ្យចូលខ្លួន ដោយមានជនជាប់ចោទឈ្មោះ [redacted] ដូនី ដែលជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ប៉េង អមជាមួយផង ការសួរចម្លើយមិនទាន់បញ្ចប់ ក៏បានបន្តនៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ។ ការសួរចម្លើយនៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ត្រូវបានបញ្ចប់នៅវេលាម៉ោងប្រហែល ១១:៣០ នាទីព្រឹក ក្រោយពីបញ្ចប់ការសួរចម្លើយហើយចៅក្រមស៊ើបសួរលោក [redacted] សុគន្ធា បានសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនជាប់ចោទឈ្មោះ [redacted] ប៉េង ដោយការសម្រេចឃុំខ្លួននេះ លោកចៅក្រមបានប្រាប់ទៅឈ្មោះ [redacted] ប៉េង និងមេធាវីឈ្មោះ [redacted] ដូនី ដោយផ្ទាល់មាត់ និងតាមកំណត់ហេតុបង្ហាញខ្លួនលើកដំបូង និងកំណត់ហេតុពិភាក្សាសួរដេញដោលចំពោះមុខ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ។ បន្ទាប់មកលោកចៅក្រមក៏បានចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ១៦៩១ ដកសឃខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ និងចេញដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៩២ ដកបឃខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ លើឈ្មោះ [redacted] ប៉េង ហើយឈ្មោះ [redacted] ប៉េង ក៏ត្រូវបានលោក [redacted] មន្ថា និងលោក [redacted] សុធា ជាមន្ត្រីនគរបាលយុត្តិធម៌នាំទៅពន្ធនាគារខេត្តកណ្ដាល ដោយមានដីកាបង្គាប់ឲ្យឃុំខ្លួនមួយសន្លឹកទៅជាមួយផង ។ ពេលនោះ



Scanned by CamScanner

ជនជាប់ចោទឈ្មោះ [redacted] ផូនី និងឈ្មោះ [redacted] ចេង ក៏បានទៅដល់ពន្ធនាគារដែរ ដោយជនជាប់ចោទឈ្មោះ [redacted] ចេង បានកំពុងជិះរថយន្ត និងនៅរង់ចាំមុខពន្ធនាគារ ហើយជនជាប់ចោទឈ្មោះ [redacted] ផូនី បានចូលទៅក្នុងពន្ធនាគារបង្កការអុកឡុក និងស្រែកគម្រាមក្នុងខណៈមន្ត្រីពន្ធនាគារលោក [redacted] ចលនា កំពុងពិនិត្យដីកាឃុំខ្លួន ហើយជនជាប់ចោទឈ្មោះ [redacted] ផូនី បានព្យាយាមឆក់ដីកាបង្គាប់ឲ្យឃុំខ្លួនពីលោក [redacted] ចលនា បណ្តាលឲ្យរហែកមួយផ្នែក ហើយក្នុងឱកាសនោះដែរ ជនជាប់ចោទឈ្មោះ [redacted] ផូនី ក៏បានបញ្ជាឲ្យឈ្មោះ [redacted] ប៉េង រត់ចេញពីពន្ធនាគារ តែពេលនោះជនជាប់ចោទឈ្មោះ [redacted] ប៉េង មិនហ៊ានរត់ចេញទេ ហើយឈ្មោះ [redacted] ផូនី ក៏បាននាំជនជាប់ចោទឈ្មោះ [redacted] ប៉េង ចេញពីពន្ធនាគារតែម្តង ដោយជនជាប់ចោទឈ្មោះ [redacted] ប៉េង បានចូលទៅជិះក្នុងរត់យន្តរបស់ជនជាប់ចោទឈ្មោះ [redacted] ចេង ម៉ាកឡិចស៊ូស ពាក់ស្លាកលេខរដ្ឋសភា ដែលកំពុងរង់ចាំនៅខាងក្រៅពន្ធនាគារ ហើយជនជាប់ចោទឈ្មោះ [redacted] ចេង ក៏បានបើករថយន្តចេញបាត់ទៅ ដោយនាំយកជនជាប់ចោទឈ្មោះ [redacted] ប៉េង ទៅជាមួយ ។

-ក្រោយពីបានពិនិត្យពិចារណារួចហើយ

<u>**យល់ឃើញថា**</u>

១-ជនជាប់ចោទឈ្មោះ [redacted] ប៉េង ត្រូវបានជាប់ចោទពីបទៈ "ការលួចរត់", ជនជាប់ចោទឈ្មោះ [redacted] ចេង និងឈ្មោះ [redacted] ផូនី ត្រូវបានជាប់ចោទពីបទៈ "ផ្តល់មធ្យោបាយលួចរត់" តាមដីកាដំណោះស្រាយបញ្ជូនរឿងឲ្យជំនុំជម្រះលេខ ២៤៣ ដកដណស្រ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ។

២-តាមរយៈការសួរដេញដោលនាពេលសវនាការ កស្តុតាងរួមមាន ៖

ក-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៉េង នៅពេលសវនាការបានឆ្លើយបដិសេធថាៈ ខ្លួនមិនបានលួចរត់នោះទេ ដោយនៅថ្ងៃទី២២ និង២៣ ខែកញ្ញា ឆ្នាំ២០១១ លោកចៅក្រមបន្ទប់លេខ៨ លោក [redacted] សុគន្ធា បានធ្វើការសាកសួររូបខ្លួន ហើយក៏ឲ្យប៉ូលិសនាំខ្លួនទៅពន្ធនាគារខេត្តកណ្តាល ខ្លួនក៏ឃើញមេធាវីខ្លួនបានទៅដែរ ហើយលោកមេធាវីខ្លួនបានជជែកដោយនិយាយថា មិនមានដីកាឃុំខ្លួនខ្លួននោះទេ ហើយលោកមេធាវី [redacted] ផូនី បានអូសដៃខ្លួនចេញ តែខ្លួនមិនព្រមចេញ ដោយខ្លួនប្រកែកមិនព្រមចេញ ដោយដើរចេញមកត្រូវមន្ត្រីពន្ធនាគារបើកទ្វារឲ្យចេញ លុះពេលចេញមកក្រៅក៏ជួបលោក [redacted] ចេង និងលោកជំទាវ [redacted] ពៅ នៅរង់ចាំខាងក្រៅ ហើយខ្លួនក៏សុំជិះទៅជាមួយ ដោយនៅក្នុងឡាននោះមានតែ០៣ នាក់ ។ នៅពេលលោកចៅក្រម [redacted] សុគន្ធា ហៅខ្លួនមកសាកសួរ គឺក្នុងនាមជាជនត្រូវចោទ គឺនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ តែដោយនៅថ្ងៃនោះ មិនបានសាកសួរទេ ដោយកំណត់ឲ្យចូលនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ពេលនោះមេធាវី [redacted] ផូនី បានប្រាប់ខ្លួនថា ឲ្យចូលទៅ លុះដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ពេលសាកសួរនោះ លោកចៅក្រម [redacted] សុគន្ធា បានប្រាប់ខ្លួនថា លោកចៅក្រមសម្រេចឃុំខ្លួនខ្លួនហើយ តែខ្លួនមើលលើដីកាឃុំខ្លួនមិនមានត្រាឈ្មោះចៅក្រមនោះទេ ។ នៅថ្ងៃនោះលោកចៅក្រមមិនបានឲ្យដីកាដល់ខ្លួនទេ ហើយនៅថ្ងៃនោះដែរ មេធាវីខ្លួន បានជជែកគ្នាជាមួយមន្ត្រីពន្ធនាគារ ។ កន្លងមកខ្លួនបានប្រាប់មេធាវី [redacted] ផូនី ថាៈ ចាំដាក់ពាក្យធានាខ្លួននៅក្រៅឃុំថ្ងៃក្រោយទៅ ។



Scanned by CamScanner

ខ-សាក្សីឈ្មោះ [redacted] ចលនា ជាមន្ត្រីពន្ធនាគារខេត្តកណ្តាល បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោងប្រហែល១២ដាង ខ្ញុំបានឃើញឈ្មោះ [redacted] មន្នា បាននាំឈ្មោះ [redacted] ប៉េង មកពន្ធនាគារ ហើយឈ្មោះ [redacted] មន្នា និងឈ្មោះ [redacted] ផ្លុង បានឈ្មោះ ប្រកែកគ្នា ហើយដណ្តើមដីកាគ្នាតែនៅក្នុងបន្ទប់រដ្ឋបាលនៅក្នុងពន្ធនាគារ នៅពេលដណ្តើមដីកាគ្នាហើយ ឈ្មោះ [redacted] ផ្លុង បានក្រៀកដៃឈ្មោះ [redacted] ប៉េង ដើរចេញពីពន្ធនាគារតែម្តង ។

គ-សាក្សីឈ្មោះ [redacted] ណាង ជាមន្ត្រីពន្ធនាគារខេត្តកណ្តាល បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃនោះ ខ្ញុំឃើញមន្ត្រីប៉ូលីសនាំឈ្មោះ [redacted] ប៉េង ចូលទៅដល់ពន្ធនាគារ ហើយប្រាប់ថាឈ្មោះ [redacted] ប៉េង មានដីកាឃុំខ្លួន ខ្ញុំក៏បានឲ្យចូលទៅក្នុងតែម្តង មួយសន្ទុះក្រោយមកខ្ញុំក៏បានឃើញឈ្មោះ [redacted] ផ្លុង ដើរចូលទៅតាមក្រោយ ហើយនៅថ្ងៃនោះដែរខ្ញុំឃើញ មានឡានចំនួនពីរគ្រឿង មានឡានមួយពាក់ស្លាកលេខរដ្ឋសភា ។

ឃ-សាក្សីឈ្មោះ [redacted] ម៉ារ៉ា ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃកើតហេតុនោះ ខ្ញុំមិនបានដឹងរឿងអ្វីខ្លះនោះទេ ខ្ញុំបានចុះលេខដីកាឲ្យគ្រប់គ្រាន់អស់ហើយ ហើយខ្ញុំបានចុះឲ្យគឺនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោងដប់ដាង ។

ង-សាក្សីឈ្មោះ [redacted] បូរី ជាបុគ្គលិកជាប់កិច្ចសន្យាសាលាដំបូងខេត្តកណ្តាល បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃនោះលោកចៅក្រមបានប្រាប់ឈ្មោះ [redacted] ប៉េង ថា: រូបលោកត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន ហើយនៅពេលលោក [redacted] ផ្លុង ចេញពីបន្ទប់នោះបានមកប្រតិកម្មជាមួយខ្ញុំថា ហេតុអ្វីបានឃុំខ្លួនកូនក្តីគាត់ ពេលខ្ញុំចេញពីបន្ទប់មកឃើញមានលោក [redacted] ខេង និងបក្សពួកគាត់ជាច្រើននាក់ ហើយខ្ញុំឃើញឈ្មោះ [redacted] ប៉េង មិនមានប្រតិកម្មអ្វីនោះទេ ខ្ញុំក៏បានឲ្យដីកាបង្គាប់ឲ្យឃុំខ្លួនមួយសន្លឹកទៅប៉ូលីសដើម្បីយកឈ្មោះ [redacted] ប៉េង ទៅពន្ធនាគារ លុះដប់ប្រាំនាទីក្រោយមកទៀត ខ្ញុំក៏បានយកដីកាបង្គាប់ឲ្យឃុំខ្លួនចំនួន ០៥សន្លឹកទៅតាមក្រោយ ដោយមានបោះត្រាត្រឹមត្រូវ នៅពេលខ្ញុំទៅដល់ពន្ធនាគារ ឃើញឈ្មោះ [redacted] ផ្លុង និយាយតួរដៃតួរជើង ហើយខ្ញុំក៏ដើរចូលទៅយកដីកាទៅឲ្យលោក [redacted] ចលនា ។

ច-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផ្លុង នៅចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ខ្ញុំបានអមកូនក្តីខ្ញុំឈ្មោះ [redacted] ប៉េង ចូលទៅឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៦០ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១ ។ មុនពេលសួរចម្លើយកូនក្តីខ្ញុំឈ្មោះ [redacted] ប៉េង បានសុំឲ្យលោកតំណាងអយ្យការ បានចូលរួមស្តាប់ចម្លើយ ពេលនោះលោក [redacted]ប៊ុនវិសុទ្ធ តំណាងអយ្យការបានចូលរួមស្តាប់ចម្លើយកូនក្តីខ្ញុំបានមួយរយៈ តំណាងអយ្យការក៏បានចាកចេញពីបន្ទប់មិនបានស្តាប់ចម្លើយកូនក្តីខ្ញុំទៀតទេ ។ ក្រោយពីតំណាងអយ្យការចេញទៅ លោកចៅក្រមស៊ើបសួរបានបន្តសួរចម្លើយកូនក្តីខ្ញុំទៀតរហូតដល់ម៉ោងប្រហែល១១ លោកចៅក្រមបានអនុញ្ញាតឲ្យកូនក្តីខ្ញុំទៅផ្ទះវិញ ប៉ុន្តែតម្រូវឲ្យកូនក្តីខ្ញុំចូលមកឆ្លើយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ម្តងទៀត ។ នៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ខ្ញុំបាននាំកូនក្តីខ្ញុំឈ្មោះ [redacted] ប៉េង ចូលមកឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួរម្តងទៀតតាមកាលកំណត់ ដោយលោកចៅក្រមបានសួរចម្លើយរហូតជិតដល់ម៉ោង១២ថ្ងៃត្រង់ទើបចប់ ពេលនោះកូនក្តីខ្ញុំត្រូវបានសមត្ថកិច្ចនាំខ្លួនទៅពន្ធនា



Scanned by CamScanner

តារខេត្តកណ្ដាល ហើយខ្ញុំក៏បានសុំដីកាសម្រេចឃុំខ្លួនពីចៅក្រមស៊ើបសួរ តែពេលនោះចៅក្រមស៊ើបសួរ មិនមានដីកាសម្រេចឃុំខ្លួនបង្ហាញខ្ញុំទេ ខ្ញុំក៏បានទាមទារយ៉ាងខ្លាំងជាច្រើនដង ប៉ុន្តែចៅក្រមមិនបាន បង្ហាញដីសម្រេចឃុំខ្លួនឲ្យខ្ញុំមើលទេ ដោយសង្កេតឃើញថាមិនមានដីកាសម្រេចឃុំខ្លួន ខ្ញុំក៏បានទៅ ពន្ធនាគារខេត្តកណ្ដាល ពេលទៅដល់ខ្ញុំឃើញកូនក្ដីខ្ញុំគេទុកនៅក្នុងបន្ទប់រដ្ឋបាលពន្ធនាគារ ខ្ញុំក៏បាន សួរមន្ត្រីពន្ធនាគារថា តើមានដីកាបង្គាប់ឲ្យឃុំខ្លួនទេ? តែពុំមានមន្ត្រីណាម្នាក់បង្ហាញដីកាបង្គាប់ឲ្យឃុំខ្លួនដល់ ខ្ញុំទេ ខ្ញុំក៏បាននិយាយថា បើមិនមានដីកាបង្គាប់ឲ្យឃុំខ្លួន មិនអាចឃុំខ្លួនកូនក្ដីខ្ញុំបានទេ ខ្ញុំក៏បានហៅ កូនក្ដីខ្ញុំឲ្យចេញក្រៅបន្ទប់ ប៉ុន្តែត្រូវបានបុរសដែលនាំកូនក្ដីខ្ញុំមកពន្ធនាគារឃាត់មិនឲ្យចេញ ហើយទាញ ទ្វារបិទដាក់គន្លឹះ ហើយខ្ញុំក៏បានចេញមកក្រៅរបងពន្ធនាគារ មកប្រាប់តំណាងរាស្ត្រលោក [redacted] ចេង ថា: ពន្ធនាគារឃុំឈ្មោះ មាស យ៉េង ដោយគ្មានដីកាបង្គាប់ឲ្យឃុំខ្លួន ហើយខ្ញុំបាននិយាយទៀតថា កាលណា គ្មានដីកាបង្គាប់ឲ្យឃុំខ្លួន ពន្ធនាគារមិនអាចឃុំខ្លួនឈ្មោះ [redacted] យ៉េង បានទេ ពេលនោះខ្ញុំក៏បានមើលម៉ោង ឃើញម៉ោង ១២.១៤ នាទី ខ្ញុំក៏បាននិយាយខ្លាំងៗថា ឯកឧត្តមជួយធ្វើសាក្សីឲ្យខ្ញុំ ថាពន្ធនាគារឃុំកូនក្ដីខ្ញុំ ដោយគ្មានដីកាបង្គាប់ឲ្យឃុំខ្លួន ។ ក្រោយពីបាននិយាយរួច ខ្ញុំក៏បានដើរចូលទៅក្នុងបរិវេណពន្ធនាគារវិញ ពេលនោះពុំឃើញអ្នកដែលនាំកូនក្ដីខ្ញុំមកពន្ធនាគារនៅទីនោះទេ ឃើញតែកូនក្ដីខ្ញុំនៅក្នុងបន្ទប់រដ្ឋបាល ពន្ធនាគារដដែល ហើយខ្ញុំបានតវ៉ាជាមួយមន្ត្រីពន្ធនាគារថា បើមិនមានដីកាបង្គាប់ឲ្យឃុំខ្លួនចេញពី តុលាការទេ ពន្ធនាគារមិនអាចឃុំខ្លួនកូនក្ដីខ្ញុំបានឡើយ បើនរណាហ៊ានឃុំខ្លួនកូនក្ដីខ្ញុំដោយគ្មានដីកា បង្គាប់ឲ្យឃុំខ្លួន ខ្ញុំនឹងប្ដឹង ។ បន្ទាប់ពីថាហើយ ខ្ញុំក៏ដើរចេញមកក្រៅពន្ធនាគារម្ដងទៀត ទៅជជែកជា មួយលោក [redacted] ចេង មួយសន្ទុះក្រោយមកក៏ឃើញបុរសម្នាក់ ជាជំនួយការក្រឡាបញ្ជី កាន់សឺមីដើរចូល យ៉ាងលឿនទៅក្នុងពន្ធនាគារ ខ្ញុំក៏បានដើរចូលទៅតាមក្រោយ ។ អ្នកកាន់សឺមីនោះបានបង្ហាញឯកសារដល់ មន្ត្រីពន្ធនាគារ ពេលនោះ ខ្ញុំក៏បានសួរអ្នកកាន់សឺមីនោះថា អូនឯងមានដីកាបង្គាប់ឲ្យឃុំខ្លួនទេ ខ្ញុំក៏សុំ មើលឯកសារក្នុងសឺមីនោះ តែបុរសនោះមិនបង្ហាញឯកសារឲ្យឃើញច្បាស់ទេ ពេលនោះខ្ញុំក៏មានចម្ងល់ ចង់ដឹងថាតើជាឯកសារអ្វី ប៉ុន្តែបុរសនោះនៅតែមិនបង្ហាញដដែល ដោយគ្រាន់តែបើកឯកសារនោះចុះ ឡើងៗ ខ្ញុំចាប់អារម្មណ៍មានឯកសារមិនទាន់ចុះហត្ថលេខា និងមិនទាន់បោះត្រាតុលាការ ពេលនោះខ្ញុំឮ សម្លេងមន្ត្រីពន្ធនាគារម្នាក់លាន់មាត់ថា: "ចុយមិនទាន់ស៊ីញ៉េ មិនទាន់បោះត្រា" ហើយមន្ត្រីពន្ធនាគារក៏បាន ដើរចេញអស់ទៅ ហើយកូនក្ដីខ្ញុំត្រូវបានគេបើកទ្វារឲ្យចេញពីបន្ទប់រដ្ឋបាល មកកន្លែងទំនាក់ទំនងព័ត៌មាន ខ្ញុំក៏បានទាមទារឯកសារ មើលម្ដងទៀត ប៉ុន្តែបុរសនោះនៅតែមិនឲ្យខ្ញុំមើល ហើយបានចាប់ឆ្នុងឯកសារដើរ ចេញមកក្រៅយ៉ាងលឿន ហើយខ្ញុំក៏បានដើរចេញតាមក្រោយ កូនក្ដីរបស់ខ្ញុំក៏ដើរតាមក្រោយខ្ញុំ ដោយពុំមានអ្នកណាឃាត់ទេ ពេលនោះខ្ញុំក៏បានឡើងជិះរថយន្តខ្ញុំ ហើយកូនក្ដីខ្ញុំដើរទៅជិះរថយន្ត របស់លោក [redacted] ង ហើយក៏បើកចេញទៅបាត់ទៅ ។

៤-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចេង នៅចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយថា: នៅថ្ងៃកើតហេតុនោះ វេលាម៉ោង១១ថ្ងៃត្រង់ ខ្ញុំបានទទួលព័ត៌មានថាឈ្មោះ [redacted] យ៉េង ត្រូវបានតុលាការសួរចម្លើយមិនទាន់ឲ្យទៅផ្ទះទេ ហើយខ្ញុំនិងលោកជំទាវ [redacted] ពៅ បាននាំគ្នាទៅមើលតែ



Scanned by CamScanner

មិនបានចូលក្នុងបន្ទប់ចៅក្រមទេ បានបន្តិចក្រោយមក ខ្លួនក៏បានឃើញមន្ត្រីនគរបាលយុត្តិធម៌នាំឈ្មោះ [redacted] យ៉េង ចេញទៅក្រៅតុលាការ ដឹកដោយរថយន្តប៉ូលិស ប៉ុន្តែខ្លួនមិនដឹងថាគេដឹកយកទៅពន្ធនាគារ ឬស្នងការនោះទេ លុះបានប្រហែលជា១៥នាទី ខ្លួនបានជិះឡានរបស់ខ្លួនទៅតាមក្រោយ នៅពេលទៅដល់ស្នងការឃើញបិទទ្វារ ខ្លួនក៏បើកឡានទៅមុខទៀត ទៅដល់មុខពន្ធនាគារខេត្ត ខ្លួនបានសួរគេ ហើយគេបានប្រាប់ថា ឈ្មោះ[redacted] យ៉េង ចូលក្នុងពន្ធនាគារខេត្តបាត់ហើយ ខ្លួនក៏បាននិយាយប្រាប់ទៅលោកជំទាវ [redacted] ពៅ ថា តូរទិញទឹក ទិញបាយឲ្យគ្នាហូបផង ស្រាប់តែពេលនោះ ខ្លួនឃើញមេធាវី [redacted] ផូង ចុះពីលើរថយន្តដើរចូលទៅក្នុងពន្ធនាគារ ។ មួយសន្ទុះក្រោយមក ខ្លួនឃើញគេបើកទ្វារឲ្យលោកមេធាវី [redacted] ផូង និងឈ្មោះ [redacted] យ៉េង ចេញមកក្រៅ ដោយពុំមានអ្នកឃាត់ ឬស្រែកឲ្យជួយចាប់ឈ្មោះ [redacted] យ៉េង ចូលទៅក្នុងពន្ធនាគារវិញទេ ហើយពេលនោះដែរ លោក[redacted]ផូង ក៏បានស្រែកប្រកាសឲ្យបងប្អូនបានដឹងឮថា កូនក្តីគាត់ពុំមានដីកាឃុំខ្លួនទេ ដូច្នេះ កូនក្តីខ្លួនគ្មានទោសអ្វីទេ និងឲ្យខ្លួនជួយធ្វើសាក្សី និងពឹងខ្លួនឲ្យជួយជូនកូនក្តីគាត់ទៅផ្ទះ ហើយខ្លួនក៏បានទទួលយកសំណើរបស់លោក [redacted] ផូង ហើយខ្លួនក៏បានដឹកឈ្មោះ [redacted] យ៉េង ចេញពីមុខពន្ធនាគារ ដោយមានលោកជំទាវ[redacted] នៅក្នុងឡានខ្លួនដែរ ។

ជ-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] បូរ៉ា ជាក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល នៅចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយបញ្ជាក់ថាៈ នៅថ្ងៃកើតហេតុនោះ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ជាថ្ងៃដែលលោកចៅក្រមស៊ើបសួរ [redacted] សុគន្ធា សួរចម្លើយឈ្មោះ [redacted] យ៉េង បន្តពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ដោយមានលោកមេធាវី[redacted] ផូង ចូលរួមស្តាប់ចម្លើយដែរ ហើយខ្លួនជាអ្នកកត់ត្រា ។ ពេលសួរចម្លើយឈ្មោះ [redacted] យ៉េង លោក[redacted] ចេង បានឈរនៅក្រៅបន្ទប់ ។ ក្រោយពីសួរចម្លើយចប់ លោកចៅក្រមបានប្រាប់ទៅឈ្មោះ [redacted] យ៉េង និងលោកមេធាវី [redacted] ផូង ថា សម្រេចឃុំខ្លួនឈ្មោះ [redacted]យ៉េង ហើយខ្លួនក៏បានធ្វើដីកាសម្រេចឃុំខ្លួនឈ្មោះ [redacted] យ៉េង តាមដីកាសម្រេចលេខ ១៦៩១ ដកសយខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ និងធ្វើដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៩៦ ដកបឃខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ហើយលោកចៅក្រមបានបញ្ជាមន្ត្រីនគរបាលឲ្យនាំឈ្មោះ [redacted] យ៉េង ទៅពន្ធនាគារខេត្តកណ្តាល និងឲ្យឈ្មោះ [redacted] បូរី កាន់ដីកាបង្គាប់ឲ្យឃុំខ្លួនទៅជាមួយ ។ នៅពេលលោកមេធាវី[redacted]ផូង ដឹងថាលោកចៅក្រមសម្រេចឃុំខ្លួនឈ្មោះ [redacted] យ៉េង ហើយ លោក [redacted] ផូង បានចេញចូលៗបន្ទប់ស៊ើបសួរ ហើយពេលនោះដែលខ្លួនបានឃើញលោក[redacted]ចេង បានឈរស្រែកនៅមាត់ទ្វារសុំទៅលោកចៅក្រម មិនឲ្យឃុំខ្លួនឈ្មោះ មាស យ៉េង ប៉ុន្តែលោកចៅក្រមថាត្រូវតែឃុំឈ្មោះ [redacted]យ៉េង នេះ ។

ឈ-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] មន្ថា ជាមន្ត្រីនគរបាលយុត្តិធម៌ នៅចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយបញ្ជាក់ថាៈ នៅថ្ងៃកើតហេតុនោះ វេលាម៉ោង១០ព្រឹក ខ្លួន និងឈ្មោះ[redacted]សុជា បានមកតុលាការតាមបញ្ជារបស់លោកចៅក្រម[redacted]សុគន្ធា ដើម្បីនាំជនត្រូវចោទឈ្មោះ [redacted] យ៉េង ទៅពន្ធនាគារខេត្តកណ្តាល ពេលមកដល់ខ្លួនបានចូលទៅក្នុងបន្ទប់របស់លោកចៅក្រម ឃើញលោកមេធាវី[redacted]ផូង និងឈ្មោះ [redacted]យ៉េង កំពុងប្រកែកគ្នាជាមួយលោកចៅក្រមពីការសម្រេចឃុំខ្លួនឈ្មោះ [redacted] យ៉េង ហើយលោកចៅក្រម បានប្រគល់ដីកាបង្គាប់ឲ្យឃុំខ្លួនមួយច្បាប់ឲ្យមកខ្លួន ឲ្យនាំឈ្មោះ [redacted] យ៉េង ទៅពន្ធនាគារ ។



Scanned by CamScanner

នៅពេលដែលខ្ញុំនាំឈ្មោះ [redacted] ប៉េង ចេញពីបន្ទប់ស្រាប់តែមានមនុស្សប្រុស និងមនុស្សស្រី ដែលឈរនៅចំពីមុខបន្ទប់លោកចៅក្រម បានសួរខ្ញុំថា នាំឈ្មោះ [redacted] ប៉េង ទៅណា? ហើយខ្ញុំឆ្លើយថា ទៅពន្ធនាគារ ពេលនោះមានលោកម្នាក់មកប្រាប់ខ្ញុំថា ឈ្មោះ [redacted] ប៉េង ជាជំទប់ឃុំទី២ឃុំបន្ទាយដែក មកពីគណបក្សសមរង្ស៊ី ជាកូនចៅរបស់គាត់ ព្រោះគាត់ជាតំណាងរាស្ត្រមណ្ឌលខេត្តកណ្ដាល ឈ្មោះ [redacted] ចេង ប្អូនឯងមិនអាចដាក់ខ្នោះ ឈ្មោះ [redacted] ប៉េង បានទេ ។ នៅពេលដែលខ្ញុំនាំឈ្មោះ [redacted] ប៉េង មកដល់ពន្ធនាគារ ខ្ញុំឃើញ មានឡានក្លូរ៉ូឡា ពណ៌ស្វារ ពាក់ស្លាកលេខ រដ្ឋសភា មកដល់ដែរ ហើយខ្ញុំឃើញនៅក្នុងឡានមាន លោក [redacted] និងលោកស្រីម្នាក់ទៀត ដែលខ្ញុំបានជួបនៅមុខបន្ទប់លោកចៅក្រម [redacted] សុគន្ធា ។ ខ្ញុំបាននាំឈ្មោះ [redacted] ទៅដល់បន្ទប់រដ្ឋបាលពន្ធនាគារ ក៏ជួបលោក [redacted] ចលនា ចំណែក លោក [redacted] សុផា នៅចាំខាងក្រៅពន្ធនាគារ ។ បន្តិចក្រោយមកខ្ញុំឃើញលោក [redacted] ជួងី ចូលមកដល់ដែរ បន្ទាប់មកឃើញឈ្មោះ [redacted] បូរី មកដល់ទៀត និងឃើញឈ្មោះ [redacted] បូរី ហុចដីកាបង្គាប់ឲ្យឃុំខ្លួនទៅឲ្យលោក [redacted] ចលនា ពិនិត្យ ភ្លាមនោះដែរ លោក [redacted] ជួងី ក៏បានស្ទុះចូលទៅកញ្ឆក់ដីកាពីដៃលោក [redacted] ចលនា បណ្ដាលឲ្យដាច់មួយផ្នែក ហើយលោកមេធាវីក៏បានចាប់អូសទាញឈ្មោះ [redacted] ប៉េង រត់ចេញទៅក្រៅពន្ធនាគារ និងស្រែកគម្រាមគេឯងថា បើអ្នកណាហ៊ានចូលមកចាប់ឈ្មោះ [redacted] ប៉េង ប្រយ័ត្នជាប់គុកទាំងអស់គ្នា រីឯខ្ញុំ និងឈ្មោះ [redacted] បូរី និងលោក [redacted] ចលនា បានរត់តាមពីក្រោយ និងស្រែកឲ្យគេជួយ ។ លុះនៅពេលដែលលោក [redacted] ជួងី បាននាំឈ្មោះ [redacted] ប៉េង ទៅដល់ក្រៅពន្ធនាគារហើយ លោក [redacted] ចេង ក៏ស្រែកសំឡុតគេឯងទៀតថា បើអ្នកណាហ៊ានចូលចាប់ឈ្មោះ [redacted] ប៉េង ត្រូវជាប់គុកទាំងអស់គ្នា ហើយលោក [redacted] ជួងី ក៏បាននាំឈ្មោះ [redacted] ប៉េង ទៅដាក់ក្នុងឡានរបស់លោក [redacted] ចេង ដែលមានមនុស្សស្រីម្នាក់ទៀតអង្គុយក្នុងឡាននោះដែរ ហើយក៏បានបើកចេញទៅបាត់តែម្ដង ។

ញ-តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] សុផា ជាមន្ត្រីនគរបាលយុត្តិធម៌ នៅចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ខ្ញុំ និងឈ្មោះ [redacted] មន្ថា បានមកតុលាការ តាមបញ្ជារបស់លោកចៅក្រម [redacted] សុគន្ធា ដើម្បីនាំឈ្មោះ [redacted] ប៉េង ទៅពន្ធនាគារខេត្តកណ្ដាល ។ ពេលមកដល់ឈ្មោះ [redacted] មន្ថា បានចូលទៅក្នុងបន្ទប់ចៅក្រម ឯខ្ញុំនៅចាំខាងក្រៅបន្ទាប់ ហើយក៏មានមនុស្សប្រុសម្នាក់មកនិយាយប្រាប់ខ្ញុំថា ប្អូនអត់ស្គាល់តំណាងរាស្ត្រខេត្តកណ្ដាលទេ បងជាតំណាងរាស្ត្រខេត្តកណ្ដាល ឈ្មោះ [redacted] ចេង ប្រាក់ខែប្អូនឯងតិចណាស់ ប្រយ័ត្នជាប់គុកមានលុយឯណាចិញ្ចឹមកូន ពេលនោះឈ្មោះ [redacted] មន្ថា បាននាំឈ្មោះ [redacted] ប៉េង ចេញពីបន្ទប់ និងលោកមេធាវី [redacted] ជួងី បានចេញមកដែរ ។ ខ្ញុំ និងឈ្មោះ [redacted] មន្ថា បាននាំឈ្មោះ [redacted] ប៉េង ទៅពន្ធនាគារ ដោយលោក [redacted] មន្ថា មានដីកាបង្គាប់ឲ្យឃុំខ្លួនឈ្មោះ [redacted] ប៉េង មួយសន្លឹក ហើយពេលទៅដល់ពន្ធនាគារ លោក [redacted] មន្ថា បាននាំឈ្មោះ [redacted] ប៉េង ចូលទៅក្នុងពន្ធនាគារ ខ្ញុំនៅចាំខាងក្រៅ ហើយខ្ញុំឃើញ លោក [redacted] ចេង និងមនុស្សស្រីម្នាក់ជិះឡានក្លូរ៉ូឡា ពាក់ស្លាកលេខ រដ្ឋសភា មកដល់មុខពន្ធនាគារដែរ មួយសន្ទុះក្រោយមកខ្ញុំក៏ឃើញ លោក [redacted] ជួងី មកដល់ពន្ធនាគារ ហើយចូលទៅក្នុងពន្ធនាគារដែរ បានប្រហែលជា ១០នាទី ក៏ឃើញលោក [redacted] ជួងី នាំឈ្មោះ [redacted] ប៉េង ចេញពីក្នុងពន្ធនាគារ ហើយឈ្មោះ [redacted] ចលនា ក៏បានស្រែកប្រាប់ខ្ញុំឲ្យជួយចាប់



Scanned by CamScanner

ឃាត់ និងរត់តាមពីក្រោយ ហើយពេលនោះដែរ លោក [redacted] ចេង ដែលចាំនៅខាងក្រៅបានស្រែកគម្រាមថា បើនណាហ៊ានចូលចាប់ឈ្មោះ [redacted] ប៉េង ប្រយ័ត្នជាប់គុកទាំងអស់គ្នា ហើយលោក [redacted] ផ្ទឌី បានស្រែកដូចលោក [redacted] ចេង ដែរ ហើយបានឲ្យឈ្មោះ [redacted] ប៉េង ចូលទៅក្នុងរថយន្តរបស់លោក [redacted] ចេង ហើយបើកចេញទៅបាត់តែម្តង ។

៣-តាមរបាយការណ៍លេខ ៤២ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ របស់ចៅក្រមស៊ើបសួរ [redacted] សុគន្ធា បានបញ្ជាក់ថា: នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ជនត្រូវចោទឈ្មោះ [redacted] ប៉េង ត្រូវបានបង្គាប់ឲ្យចូលខ្លួនមកសួរចម្លើយពីបទ: "ផ្តួចផ្តើមគំនិតប្រើអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត" ដោយបានចូលខ្លួនមកអមជាមួយលោកមេធាវី [redacted] ផ្ទឌី ។ ហើយលោកចៅក្រម បានធ្វើកំណត់ហេតុបង្ហាញខ្លួនលើកដំបូង និងកំណត់ហេតុសួរដេញដោយចំពោះមុខ ដោយការសួរចម្លើយ មានវត្តមានលោកព្រះរាជអាជ្ញារង [redacted] ប៊ុនវិសុទ្ធ លោកក្រឡាបញ្ជី [redacted] បូរ៉ា និងលោក [redacted] បូរី ជាជំនួយការ ។ ការសួរចម្លើយឈ្មោះ [redacted] ប៉េង នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ មិនទាន់បញ្ចប់ លោកចៅក្រមបានប្រាប់ឲ្យចូលខ្លួនមកឆ្លើយបន្តនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ លុះនៅព្រឹកថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ការសួរចម្លើយឈ្មោះ [redacted] ប៉េង បានបន្ត និងបានបញ្ចប់ការសួរចម្លើយនៅម៉ោងប្រហែលជា ១១:៣០ នាទីព្រឹក ក្រោយពីសួរចម្លើយចប់ លោកចៅក្រម [redacted] សុគន្ធា បានប្រាប់ទៅឈ្មោះ [redacted] ប៉េង នៅចំពោះមុខមេធាវី [redacted] ផ្ទឌី អំពីការសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ។ បន្ទាប់មកលោកចៅក្រមបានចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ ១៦៩១ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ និងដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៩២ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ពេលកំពុងវាយត្រាលើដីកាទាំងពីរ លោកចៅក្រមបានឃើញលោក [redacted] ចេង និងស្ត្រីម្នាក់ បានឈរនៅមុខបន្ទប់ ហើយបានប្រាប់លោកចៅក្រមថា គាត់ឈ្មោះ [redacted] ចេង ជាតំណាងរាស្ត្រខេត្តកណ្តាល សុំឲ្យលោកចៅក្រមបន្ធូរដៃ ។ បន្ទាប់មកលោកចៅក្រមបានប្រគល់ដីកាបង្គាប់ឲ្យឃុំខ្លួនឈ្មោះ [redacted] ប៉េង មួយសន្លឹក ទៅលោក [redacted] មន្ថា ជាមន្ត្រីនគរបាលយុត្តិធម៌ និងមានលោក [redacted] សុធា ជាមន្ត្រីនគរបាលយុត្តិធម៌ដែរ ។ ភ្លាមនោះលោក [redacted] មន្ថា បានចូលមកបន្ទប់លោកចៅក្រមតាមបញ្ជារបស់លោកចៅក្រមដើម្បីនាំឈ្មោះ [redacted] ប៉េង ទៅឃុំខ្លួននៅពន្ធនាគារ និងដាក់ខ្នោះដៃលោក [redacted] ប៉េង ប៉ុន្តែ លោក [redacted] ប៉េង បានសំណូមពរថា កុំដាក់ខ្នោះខ្លួនអី ខ្លួនមិនរត់ទៅណាទេ លោកចៅក្រមក៏បានទទួលសំណូមពរ ប៉ុន្តែលោកមេធាវី [redacted] ផ្ទឌី បានតវ៉ាយ៉ាងខ្លាំងក្លាអំពីរឿងសម្រេចឃុំខ្លួននេះ និងបាននិយាយថា ខ្លួននឹងប្តឹងអំពីរឿងនេះ ។ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ទាំងពីរនាក់បាននាំឈ្មោះ [redacted] ប៉េង ទៅដល់ពន្ធនាគារ មួយសន្ទុះក្រោយមក លោក [redacted] បូរី ដែលជាជំនួយការ បានទូរស័ព្ទពីពន្ធនាគារមកប្រាប់លោកចៅក្រមថា លោកមេធាវី [redacted] ផ្ទឌី បានតវ៉ាជាមួយមន្ត្រីពន្ធនាគារថាឃុំខ្លួនមនុស្សគ្មានដីកាសម្រេច ដីកាមិនត្រឹមត្រូវ ហើយបានដណ្តើមដីកាពីលោក [redacted] ចលនា ជាមន្ត្រីពន្ធនាគារ និងបានអូសយកឈ្មោះ [redacted] ប៉េង ចេញពីពន្ធនាគារទៅដាក់ចូលក្នុងឡានរបស់លោក [redacted] ចេង ដែលបានកំពុងរង់ចាំនៅខាងមុខពន្ធនាគារ ហើយបានបើកចេញទៅបាត់ដោយនាំយកឈ្មោះ [redacted] ប៉េង ទៅជាមួយ ។



Scanned by CamScanner

៨-តាមរយៈដីសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ១៦៩១ ដកសយខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ និងដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៦៩៨ ដកបយខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ឃើញថាៈ ដីបង្គាប់ឲ្យឃុំខ្លួន ១៦៩៨ ដកបយខ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ ត្រូវបានរហែក មួយផ្នែកខាងក្រោមដីកា ។

៩-តាមកំណត់ហេតុបង្ហាញខ្លួនលើកដំបូង និងកំណត់ហេតុពិភាក្សាសួរដេញដោលចំពោះមុខ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១១ មានគូសធិចត្រង់ចំណុច យើងបានប្រាប់ដល់ជនត្រូវចោទថា យើងមានបំណងសម្រេចឃុំខ្លួនគាត់ជាបណ្ដោះអាសន្ន និងគូសត្រង់ចំណុច យើងក៏បញ្ជាក់ប្រាប់ជនត្រូវចោទដែរថា យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃនេះ ។

៦-តាមរយៈការពិនិត្យភស្តុតាង, របាយការណ៍របស់លោកចៅក្រមស៊ើបសួរ [redacted] សុគន្ធា, ចម្លើយរបស់សាក្សីទាំងអស់ ព្រមទាំងចម្លើយរបស់ជនជាប់ចោទទាំង០៣នាក់ បញ្ជាក់ឲ្យឃើញថាៈ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ នៅចំណុចពន្ធនាគារខេត្តកណ្ដាល ពិតជាមានអំពើ លួចរត់ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] ប៉េង ព្រមទាំងមានការផ្ដល់មធ្យោបាយក្នុងការលួចរត់របស់ឈ្មោះ [redacted] ប៉េង នេះ ដែលប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ផូនី និងឈ្មោះ [redacted] ខេង ប្រាកដមែន ។

៧-ជនជាប់ចោទឈ្មោះ [redacted] ប៉េង នាពេលសវនាការ បានឆ្លើយបដិសេធថាៈ ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះ គ្រាន់តែជាការដោះសាររកលេសឲ្យរួចពីការចោទប្រកាន់តែប៉ុណ្ណោះ ដោយពុំមានភស្តុតាង ឬសាក្សីណាមកបញ្ជាក់ឲ្យតុលាការជឿបានដែរ ព្រោះថាៈ ជនជាប់ចោទឈ្មោះ [redacted] ប៉េង បន្ទាប់ពីលោកចៅក្រមស៊ើបសួរ [redacted] សុគន្ធា បានធ្វើការសួរចម្លើយរួច លោកចៅក្រមបានជូនដំណឹងអំពីការសម្រេចឃុំខ្លួនទៅដល់ឈ្មោះ [redacted] ប៉េង នៅចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផូនី ជាមេធាវីការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ប៉េង និងតាមរយៈកំណត់ហេតុបង្ហាញខ្លួនលើកដំបូង និងកំណត់ហេតុពិភាក្សាសួរដេញដោលចំពោះមុខ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១១ បន្ទាប់ពីបានទទួលដំណឹងអំពីការសម្រេចឃុំខ្លួននេះ ក៏មានការប្រកែកតវ៉ាពីសំណាក់ជនជាប់ចោទឈ្មោះ [redacted] ផូនី ដែលជាមេធាវីការពារឲ្យឈ្មោះ [redacted] ប៉េង ។ ជនជាប់ចោទឈ្មោះ [redacted] ប៉េង បន្ទាប់ពីបានដឹងខ្លួនថាលោកចៅក្រមសម្រេចឃុំខ្លួនហើយ ក៏បានសំណូមពរទៅដល់លោកចៅក្រមមេត្តាកុំដាក់ខ្នោះខ្លួន ហើយពេលទៅដល់ក្នុងបន្ទប់រដ្ឋបាលពន្ធនាគារខេត្ត ជំបូងឡើយ ទោះបីជាជនជាប់ចោទឈ្មោះ [redacted] ផូនី អូសដៃជនជាប់ចោទឈ្មោះ [redacted] ប៉េង ឲ្យចេញក្រៅយ៉ាងណា ក៏ឈ្មោះ [redacted] ប៉េង មិនព្រមចេញដែរ ដោយបានប្រាប់ឈ្មោះ [redacted] ផូនី ថា ខ្លាចខុសច្បាប់ តែចុងក្រោយគឺជនជាប់ចោទឈ្មោះ [redacted] ប៉េង បានចេញពីពន្ធនាគារទៅតាមជនជាប់ចោទឈ្មោះ [redacted] ផូនី ហើយចូលទៅជិះក្នុងរថយន្តរបស់ជនជាប់ចោទឈ្មោះ [redacted] ខេង ហើយបើកចេញទៅបាត់ទៅ ដូច្នេះ ឃើញថាៈ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប៉េង មានធាតុផ្សំគ្រប់គ្រាន់កំណត់បានជាបទល្មើស ការលួចរត់ បានហើយ ដែលជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥២០, ៥២១ នៃក្រមព្រហ្មទណ្ឌ ។



Scanned by CamScanner

៣-ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈ ០២ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល ។

ពីបទៈ "ផ្តល់មធ្យោបាយលួចរត់" ប្រព្រឹត្តនៅចំណុចពន្ធនាគារខេត្តកណ្តាល ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥៦៥ នៃក្រមព្រហ្មទណ្ឌ ។

ខ-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៉េង និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ចំពោះមុខលោកមេធាវី [redacted] សំអឿន ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផ្លី និងចំពោះមុខលោកមេធាវី [redacted] លន់ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ហេង, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៉េង, ជនជាប់ចោទឈ្មោះ [redacted] ផ្លី និងជនជាប់ចោទឈ្មោះ តាន់ ហេង, ព្រមទាំងកំបាំងមុខលោកមេធាវី ពុធ ធារី, លោកមេធាវី [redacted] ផុនធី, លោកមេធាវី [redacted] មុនិន្ទ, លោកមេធាវី [redacted]ណ្ណា, លោកមេធាវី [redacted] បញ្ញា, លោកមេធាវី [redacted] សារី និងលោកមេធាវី ស៊ុយ ឈុនហាក់ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផ្លី និងកំបាំងមុខលោកមេធាវី [redacted] ឃី និងលោកមេធាវី [redacted] វុទ្ធី ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ហេង ។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned by CamScanner